**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**ក្រុមលទ្ធកម្ម**

លេខ : ០៩១ ក.ល

មានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការលាបពណ៌អគារសាលាដំបូងឡើងវិញ និងតម្លើងជណ្តើរយន្ត ជូនសាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា សាលាដំបូងរាជធានីភ្នំពេញ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារ**លាបពណ៌អគារសាលាដំបូងឡើងវិញ និងតម្លើងជណ្តើរយន្ត ជូនសាលាដំបូងរាជធានីភ្នំពេញ** ។

សាលាដំបូងរាជធានីភ្នំពេញ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្មសាលាដំបូងរាជធានីភ្នំពេញ ដែលមានអាសយដ្ឋានអគារលេខ ២៥ ផ្លូវ ២១៧ កែង ២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ ០១២ ៩៦៣ ១៤៤/០៩២ ២៧៩ ៧៦៧) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ០៩:០០ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលាដំបូងរាជធានីភ្នំពេញ តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩:០០ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មសាលាដំបូងរាជធានីភ្នំពេញ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ពុធ ១០ កើត ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៨

**ប្រធានសាលាដំបូងរាជធានីភ្នំពេញ**
**និងជាប្រធានក្រុមលទ្ធកម្ម**

**តាំង-ស៊ុនឡាយ**

**ចម្លងជូន ៖**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ